ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១១៧ ព.ណ.ខរ.បក

# ប្រកាស
# ស្តីពី
# ការបង្កើតក្រុមការងារបច្ចេកទេស វិមជ្ឈការ និងវិសហមជ្ឈការ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅនៃក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ២០១២ ស្តីពីដំណើរការទូទៅនៃការផ្ទេរមុខងារ និងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងសេចក្តីសម្រេចលេខ១០៥ ស.ស.រ/ គ.ជ.អ.ប ចុះថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១២ ស្តីពីការដាក់ឲ្យប្រើប្រាស់នូវសេចក្តីណែនាំស្តីពីការរៀបចំបញ្ជីវិភាគមុខងាររបស់ក្រសួង ស្ថាប័នមន្ទីរ អង្គភាពនានា និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់
- យោងលិខិតលេខ០១១ សជណ/ គ.ជ.អ.ប ចុះថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០១៥ ស្តីពីការបង្កើតក្រុមការងារវិមជ្ឈការ និងវិសហមជ្ឈការ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គ.ជ.អ.ប

## សម្រេច

**ប្រការ ១៖** បង្កើតក្រុមការងារបច្ចេកទេស វិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួងពាណិជ្ជកម្ម ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១-ឯកឧត្តម **គឹម ស៊ីថន** | រដ្ឋលេខាធិការ | ប្រធាន |
| ២-ឯកឧត្តម **ឃឹម សិរីវង្ស** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣-លោក **រតន៍ សាម៉ន** | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |

| | | |
|---|---|---|
| ៤-លោក **ឃឹម វុំសុវាន** | ប្រធាននាយកដ្ឋានបុគ្គលិក | សមាជិក |
| ៥-លោក **សេខ សុឡាឌី** | អនុប្រធាននាយកដ្ឋានគណនេយ្យ | សមាជិក |
| ៦-លោក **មុី ម៉ុនលី** | អនុប្រធាននាយកដ្ឋានបុគ្គលិក | សមាជិកអចិន្ត្រៃយ៍ |
| ៧-លោក **ស៊ូ ម៉ច់** | ប្រធានការិយាល័យ | សមាជិក |
| ៨-លោក **ផន ស៊ីន** | អនុប្រធានការិយាល័យ | សមាជិក |

**ប្រការ ២ ៖** ក្រុមការងារបច្ចេកទេស វិមជ្ឈការ និងវិសហមជ្ឈការ មានភារកិច្ចដូចតទៅ៖
-សម្របសម្រួល និងសហការដោយផ្ទាល់ និងជាប្រចាំជាមួយនឹងលេខាធិការដ្ឋាន គ.ជ.អ.ប
-សមាជិកក្រុមការងារនេះ ត្រូវចូលរួមប្រជុំគ្រប់ការអញ្ជើញរបស់ប្រធានក្រុម

**ប្រការ ៣ ៖** នាយកខុទ្ទកាល័យ ឯកឧត្តម លោក លោកស្រី ដែលមានឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តតាមប្រកាសនេះឲ្យមានប្រសិទ្ធិភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ,ថ្ងៃទី ២០ ខែ មីនា ឆ្នាំ២០១៥

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

ស៊ុន ចាន់ថុល

**ចម្លងជូន៖**

-លេខាធិការដ្ឋាន គ ជ អ ប
-ក្រុមការងារ គ ជ អ ប ក្រសួង
-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
(ដើម្បីជ្រាបជាព័ត៌មាន)
-ក្រុមគាំទ្រកម្មវិធី នៃលេខាធិការដ្ឋាន គ.ជ.អ.ប
(ដើម្បីសហការអនុវត្ត)
-ដូចប្រការ៣ (ដើម្បីអនុវត្ត)
-ឯកសារ-កាលប្បវត្តិ